# សំណួរដែលគេឧស្សាហ៍សួរអំពី ការសិក្សាដោយផ្អែកលើផែនការជាក់ស្តែង/Project-Based Learning

# របស់សាលាបឋមសិក្សា ខាណេល្ល (Carnell)

«សិក្សាតាមរយៈការអនុវត្តន៍ផ្ទាល់/hands-on learning» «ស្វែងយល់ចម្លើយទៅនឹងសំណួររបស់ខ្លួន»

**ខ្ញុំបានឮអំពី «ការរៀបចំឡើងវិញ/redesign» របស់សាលា ខាណេល្ល។ តើនេះមានន័យថា ពួកគេនឹងទៅជាសាលាឆាធ័រនៅឆ្នាំក្រោយឬអ្វី?**

អត់ទេ។ សាលា ខាណេល្ល នឹងនៅតែជាសាលាក្នុងតំបន់របស់ក្រសួងអប់រំ។ ក្មេងដែលមានសិទ្ធិរៀននៅសាលា ខាណេល្ល ឆ្នាំនេះ នឹងមានសិទ្ធិរៀននៅឆ្នាំក្រោយទៀត។ សាលា ខាណេល្ល នៅតែជាសាលាក្នុងតំបន់របស់ក្រសួងអប់រំ សម្រាប់តំបន់នេះ។ សាលា ខាណេល្ល គឺជាសាលាមួយ ក្នុងចំណោមសាលាបួនរបស់ក្រសួងអប់រំ ដែលគេបានជ្រើសរើសដើម្បីរៀបចំឡើងវិញនៅឆ្នាំនេះ។ នេះមានន័យថា វិធីដែលយើង បង្រៀន និង អនុវត្ត នៅសាលាឆ្នាំក្រោយនឹងមានភាពខុសប្លែកយ៉ាងខ្លាំង។ សាលា ខាណេល្ល នឹងរៀបចំឲ្យក្លាយទៅជាសាលា Project Based Learning នៅខែកញ្ញា ឆ្នាំ២០១៥។

**តើការ សិក្សាដោយផ្អែកលើផែនការជាក់ស្តែង/Project Based Learning (PBL) គឺជាអ្វី?**

វាគឺជាសកម្មភាពនៃការសិក្សាតាមរយៈនៃការស្វែងយល់អំពីបញ្ហាពិតៗ និងការបង្កើតដំណោះស្រាយសម្រាប់បញ្ហានោះ។ ក្មេងនឹងបង្ហាញនូវអ្វីៗដែលពួកគេសិក្សា នៅពេលដែលពួកគេរៀនពីជំពូកនីមួយៗ មិនមែននៅពេលដែលពួកគេរៀនចប់នោះទេ។ នៅក្នុង PBL ក្មេងសិក្សាអំពីប្រធានបទខុសៗគ្នាជាច្រើន ក្នុងពេលតែមួយ – អ្វីៗទាំងអស់ គឺជាការស្រាវជ្រាវអំពីបញ្ហាពិតៗដែលពួកគេបានរកឃើញ។

**ហេតុអ្វីបានជាជ្រើសយក PBL?**

សិស្សានុសិស្សនឹងមានការយល់ដឹងយ៉ាងជ្រាលជ្រៅអំពី គំនិត និង ស្តង់ដា ក្នុងជម្រៅនៃគម្រោងផែនការនីមួយៗ។ គម្រោងផែនការ ក៏អាចបណ្តុះនូវចំណេះដឹងដ៏សំខាន់សម្រាប់កន្លែងធ្វើការ និងទម្លាប់នៃការសិក្សានៅក្នុងជីវិតរស់នៅ។ គម្រោងផែនការ អាចឲ្យសិស្សានុសិស្សដោះស្រាយបញ្ហានៅក្នុងសហគមន៍ ស្វែងយល់ពីអាជីពផ្សេងៗ ធ្វើទំនាក់ទំនងជាមួយអ្នកជួយណែនាំ ប្រើប្រាស់បច្ចេកវិទ្យា និង ពន្យល់បង្ហាញកិច្ចការរបស់ពួកគេ ដល់ទស្សនិកជន លើសពីថ្នាក់រៀនទៅទៀត។ PBL អាចជួយលើកទឹកចិត្តដល់សិស្សានុសិស្សដែលធុញទ្រាន់នឹងសាលា ឬ យល់ថាសាលាគ្មានន័យ។

**តើកូនខ្ញុំនឹងសិក្សាអំពីអ្វីៗគ្រប់បែបយ៉ាងដែលពួកគេត្រូវចេះ តាមរយ: PBL នេះឬទេ?**

នឹងសិក្សា។ ការសិក្សាមុខវិជ្ជាច្បាស់លាស់អំពី គំនិត និង ស្តង់ដា (TEKS) គឺជាគោលបំណងសំខាន់បំផុតនៃ PBL។ គម្រោងផែនការនឹងចាប់ផ្តើមឡើងជាមួយកម្មវិធីសិក្សាទូទៅ និងប្រើការវាយតម្លៃដែលសមស្រប ដើម្បីបញ្ជាក់នូវអ្វីៗដែលសិស្សានុសិស្សបានសិក្សា។ បន្ទាប់មក គម្រោងផែនការ ត្រូវបានរៀបចំឡើងតាមសំណួរដែលបានចោទឡើង (Driving Question) ដែលវិញបញ្ចូលគ្នារវាង លទ្ធផល និង សកម្មភាពនៃគម្រោងផែនការ ដែលគេបានបម្រុងទុក។

**តើគេនឹងឲ្យពិន្ទុកូនខ្ញុំដោយរបៀបណា?**

គេនឹងប្រើក្បួនខ្នាតនៃការឲ្យពន្ទុ (rubrics)ដើម្បីឲ្យពិន្ទុដល់ការចូលរួមជាមួយក្រុម គុណភាពនៃកិច្ចការ និង ការពន្យល់បង្ហាញរបស់សិស្សម្នាក់ៗ។ គេក៏នឹងឲ្យពិន្ទុនៃការព្យាយាមធ្វើកិច្ចការរបស់សិស្សម្នាក់ៗ ប្រចាំសប្តាហ៍។ សិស្សានុសិស្សក៏នឹងទទួលពិន្ទុផ្ទាល់ខ្លួនដោយឡែកៗពីគ្នា តាមរយៈនៃការវាយតម្លៃតាមទម្លាប់ រួមមាន ការប្រឡង សំណួរខ្លីៗ ធ្វើកិច្ចការខ្លីៗ និង ការប្រឡង benchmarks។

**តើគ្រូនឹងត្រៀមខ្លួនដើម្បីបង្រៀនតាមគំរូថ្មីនេះដោយវិធីណា?**

ពីរបីខែកន្លងមកនេះ សាលា ខាណេល្ល បានរៀនចំសិក្ខាសាលាសម្រាប់ការហ្វឹកហ្វឺនផ្នែកការងារដល់គ្រូ ដោយផ្តោតទៅលើ PBL និងរៀនរបៀបបង្រៀនតាមបែប គម្រោងផែនការ។ យើងខ្ញុំកំពុងរៀបចំការអនុវត្តន៍ពេញថ្ងៃខ្លះទៀត ដែលនឹងផ្តោតទៅលើអ្វីៗទាំងអស់នេះផងដែរ។ គ្រូនឹងបន្តការហ្វឹកហ្វឺនរបស់ខ្លួននៅរដូវក្តៅ ធ្វើបែបនេះ យើងនឹងមានគ្រូដែលបានរៀនពីរបៀបអនុវត្តគំរូនេះយ៉ាងច្បាស់លាស់ នៅពេលសាលាបើកនៅខែកញ្ញា។ ជាបន្ថែមទៀត ដោយសារសាលា ខាណេល្ល មានការផ្លាស់ប្តូរយ៉ាងច្រើន យើងត្រូវធ្វើយ៉ាងណាឲ្យគ្រូទាំងអស់ចូលរួមក្នុងកម្មវិធី PBL។ ដល់ទីបញ្ចប់ គេនឹងសុំឲ្យគ្រូម្នាក់ៗដែលចង់បង្រៀននៅសាលា ខាណេល្ល ធ្វើសម្ភាស៍ជាថ្មី ដើម្បីឲ្យស្របទៅតាមតម្រូវការទាំងនេះ។ យើងខ្ញុំក៏នឹងសហការជាមួយអង្គការដែលជាដៃគូក្នុងការបង្កើតកម្មវិធីសិក្សាដែលមានបទពិសោធន៍ក្នុងការជួយផ្លាស់ប្តូរសាលា ពីគំរូចាស់ ទៅជាគំរូ PBL។ ពួកគេនឹងផ្តល់ការហ្វឹកហ្វឺនផ្នែកការងារដល់បុគ្គលិក និងអ្នកបង្ហាត់គ្រូ របស់យើង។

**តើធ្វើដូចម្ដេចទើបដឹងថា កូនរបស់ខ្ញុំដឹងយល់ពីមុខវិជ្ជា (ការវាយតម្លៃ)?**

ចៀសជាងការប្រឡងតែម្ដងនៅពេលចប់ជំពូកនីមួយៗ PBL ពាក់ព័ន្ធនឹងការវាយតម្លៃជាច្រើនដង (ការវាយតម្លៃជាបន្តបន្ទាប់)។ ការវាយតម្លៃទាំងនេះ ខ្លះអាចជាការប្រឡងតាមទម្លាប់ធម្មតា ប៉ុន្តែជាញឹកញាប់ សិស្សានុសិស្សនឹងវាយតម្លៃគ្នាទៅវិញទៅមកតាមក្បួនខ្នាតនៃការឲ្យពិន្ទុ (rubrics) ដែលបានរៀបចំឡើង ដើម្បីវាយតម្លៃចំណេះដឹងក្នុង ការសហការគ្នា ការព្យាយាមធ្វើកិច្ចការ និង សមត្ថភាពយល់ដឹងលើមុខវិជ្ជា។ ការធ្វើដូច្នេះ អាចឲ្យសិស្សានុសិស្សដឹងពី ចំណុចខ្លាំង និង ចំណុចខ្សោយ របស់ខ្លួន ហើយអាចធ្វើការផ្លាស់ប្ដូរដែលចាំបាច់ ដើម្បីទទួលចំណេះដឹងដែលពួកគេត្រូវការ។ ជាបន្ថែមទៀត គេនឹងអញ្ជើញមាតាបិតាឲ្យមកចូលរួមប្រជុំជាប្រចាំ ដើម្បីរៀបចំផែនការ។ អង្គប្រជុំទាំងនេះនឹងដឹកនាំដោយសិស្ស - ដែលអាចជួយសិស្សានុសិស្សឲ្យមាន ភាពម្ចាស់ការ និង ការទទួលខុសត្រូវ ចំពោះការសិក្សារបស់ខ្លួនផ្ទាល់។ អ្វីៗទាំងនេះ មានការត្រួតពិនិត្យ និង ណែនាំដោយគ្រូប្រចាំថ្នាក់។

**កូនខ្ញុំមាន IEP (គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ)។ តើពួកគេនៅតែទទួលការបម្រើនេះតទៅទៀតឬទេ?**

នឹងទទួល។ បើសិនជាកូនលោកអ្នកទទួលការអប់រំពិសេស ពួកគេនៅតែទទួលជំនួយទាំងនេះ។ បុគ្គលិកផ្នែកអប់រំពិសេសរបស់យើងខ្ញុំនឹងសហការជាមួយគ្រូរបស់កូនលោកអ្នក ដើម្បីធ្វើយ៉ាងណាឲ្យកិច្ចការរបស់ពួកគេ កាន់តែបង្កើនគោលដៅនៃការសិក្សារបស់ពួកគេតទៅទៀត។ បើសិនជាចាំបាច់ គេអាចយកកូនលោកអ្នកចេញពីថ្នាក់រៀន ដើម្បីផ្ដល់ការបង្ហាត់បង្រៀនបន្ថែមក្នុងមុខវិជ្ជាអ្វីមួយ ឬ គ្រូដែលផ្ដល់ការអប់រំពិសេសអាច «ចូលរួម» ក្នុងថ្នាក់របស់កូនលោកអ្នក ហើយបង្រៀនរួមគ្នាជាមួយគ្រូក្នុងថ្នាក់ តាមវិធីដែលអាចជួយឲ្យមានជោគជ័យ តាមផែនការនៃការអប់រំរបស់កូនលោកអ្នក។

**កូនរបស់ខ្ញុំទទួលជំនួយសម្រាប់ សិស្សដែលត្រូវការរៀនភាសាអង់គ្លេស (ELL)។ តើគេនៅតែទទួលជំនួយនេះតទៅទៀតឬទេ?**

នឹងទទួល។ ស្រដៀងគ្នានឹងកម្មវិធីអប់រំពិសេសរបស់យើងខ្ញុំដែរ បុគ្គលិក ELL របស់យើងនឹងយកសិស្សចេញពីថ្នាក់ដើម្បីជួយបង្ហាត់បង្រៀនបន្ថែម និង គ្រូចូលរួមក្នុងថ្នាក់របស់កូនលោកអ្នក ដើម្បីធ្វើយ៉ាងណាឲ្យសិស្សទាំងអស់របស់យើងរៀនបានតាមផែនការនៃការសិក្សារបស់ពួកគេ និងមានការរីកចម្រើនឡើង។

**តើខ្ញុំត្រូវទាក់ទងទៅអ្នកណា បើសិនជាកូនខ្ញុំមានការលំបាកក្នុងការធ្វើកិច្ចការអ្វីមួយ?**

បើសិនជាសិស្សមានការលំបាកក្នុងការធ្វើកិច្ចការអ្វីមួយ សិស្សត្រូវនិយាយជាមួយគ្រូ។ បើសិនជាត្រូវការ ការធ្វើអន្តរាគមន៍បន្ថែមទៀត មាតាបិតាត្រូវទាក់ទងទៅគ្រូ។

**តើសមាសភាគនៃ PBL មានអ្វីខ្លះ?**

- សំណួរដែលបានចោទឡើង (Driving Question)
- ឯកសារចាប់ផ្ដើម (Entry Document)
- កិច្ចព្រមព្រៀងជាក្រុម (Groups/Social Contracts)
- សេចក្ដីរៀបរាប់អំពីបញ្ហា (Problem Statements)
- បញ្ជីដែលបង្ហាញពី «អ្វីដែលចេះហើយ» និង «អ្វីដែលត្រូវចេះ»
- ធ្វើគម្រោង/សិក្ខាសាលា (Scaffolding/Workshops)
- កិច្ចការ (Project)
- បទបង្ហាញ (Presentations)
- គំនិតឆ្លុះបញ្ចាំង (Reflection)

**ខ្ញុំពិតជារំភើបចិត្តអំពីការផ្លាស់ប្ដូរនេះណាស់! តើមានវិធីអ្វីដែលមាតាបិតាអាចចូលរួមបានដែរឬទេ?**

យើងខ្ញុំរីករាយណាស់ដែលលោកអ្នកសួរសំណួរនេះ! PBL ផ្ដល់ការចូលរួមរបស់មាតាបិតាតាមវិធីដែលគំរូផ្សេងទៀតមិនមាន។ យើងខ្ញុំត្រូវការឲ្យមាតាបិតាចូលរួមជា អ្នកជំនួយក្នុងថ្នាក់ ជាទស្សនិកជន និង ជាមេប្រយោគ សម្រាប់ការពន្យល់បង្ហាញរបស់សិស្ស អ្នកឯកទេសផ្នែកកិច្ចការក្នុងថ្នាក់ សមាជិកក្រុមប្រឹក្សា ហើយជាពិសេស គឺជាអ្នកជួយអបអរ និង ជាអ្នកគាំទ្រ ដល់កូនរបស់លោកអ្នកនៅផ្ទះ។ បើសិនជាលោកអ្នករំភើបចិត្តអំពីឱកាសទាំងនេះ ប៉ុន្តែមិនសូវមានបទពិសោធន៍ សូមកុំភ័យ! មណ្ឌលផ្ដល់ជំនួយដល់ក្រុមគ្រួសារ របស់យើងខ្ញុំនឹងផ្ដល់ការហ្វឹកហ្វឺនដែលលោកអ្នកត្រូវការ ដើម្បីជួយដល់អ្នកអប់រំរបស់យើង។

**ពិតមែនហើយ ឥឡូវនេះចង់ដឹងណាស់ៗ តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពី PBL នៅទីណា?**

វិបសៃពីរខាងក្រោមនេះ មានព័ត៌មានសំខាន់ៗអំពី PBL៖

http://www.bie.org/
http://www.newtechnetwork.org/